## វិធានការបន្ទាន់

- រដ្ឋាភិបាលទាំងឡាយ ត្រូវធ្វើការសំរេចចិត្តដ៏ពិបាកក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩។ ច្បាប់អន្តរជាតិអនុញ្ញាតិឱ្យមានវិធានការបន្ទាន់ ក្នុងការឆ្លើយតបទៅនឹងការគំរាមកំហែងសំខាន់ៗ ប៉ុន្តែវិធានការដែលរឹតត្បិតសិទ្ធិមនុស្ស គួរតែមានសមាមាត្រទៅនឹងហានិភ័យដែលបានធ្វើការវាយតម្លៃ ចាំបាច់ ហើយត្រូវបានអនុវត្តដោយមិនរើសអើង។ នេះមានន័យថា មានការផ្តោត និងរយៈពេលជាក់លាក់ ហើយប្រកាន់យកអភិក្រមជ្រៀតជ្រែកតិចបំផុត ដើម្បីការពារសុខភាពសាធារណៈ។
- នៅពេលដែលរដ្ឋទាំងឡាយប្រកាសភាពអាសន្ន រដ្ឋដែលជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គួរតែបំពេញតាមកាតព្វកិច្ចផ្លូវច្បាប់របស់ខ្លួន ដើម្បីផ្តល់ការជូនដំណឹងជាផ្លូវការ តាមរយៈអគ្គលេខាធិការ អ.ស.ប ។ សន្ធិសញ្ញាសិទ្ធិមនុស្សក្នុងតំបន់ រួមមាន កាតព្វកិច្ចស្រដៀងគ្នានេះ។
- ទាក់ទងទៅនឹងជំងឺកូវីដ-១៩ អំណាចគ្រាអាសន្ន ត្រូវបានប្រើតែដើម្បីគោលដៅសុខភាពសាធារណៈស្របច្បាប់ មិនត្រូវប្រើជាមូលដ្ឋាន ដើម្បីបង្ក្រាបមតិជំទាស់ បំបិទសិទ្ធិការងារអ្នកការពារសិទ្ធិមនុស្ស ឬអ្នកសារព័ត៌មាន បដិសេធសិទ្ធិមនុស្សដទៃទៀត ឬចាត់វិធានការដទៃផ្សេងទៀត ដែលមិនចាំបាច់ខ្លាំងក្នុងការដោះស្រាយស្ថានភាពសុខភាព។ សិទ្ធិមួយចំនួន មិនអាចរឹតត្បិតបានឡើយ សូម្បីតែនៅក្នុងគ្រាអាសន្នក្តី (មិនអាចបដិសេធបាន) រួមទាំង គោលការណ៍មិនបញ្ជូនត្រឡប់ទៅវិញ ការហាមឃាត់ការបណ្តេញជាសមូហភាព ការហាមឃាត់ការធ្វើទារុណកម្ម និងការធ្វើបាប ការរំលោភសិទ្ធិសេរីភាពខាងគំនិត សតិសម្បជញ្ញៈ និងសាសនា និងសិទ្ធិផ្សេងទៀត។
- រដ្ឋាភិបាលទាំងឡាយ គួរជូនដំណឹងដល់ប្រជាជនដែលរងផលប៉ះពាល់ពីវិធានការបន្ទាន់ កន្លែងដែលវិធានការនោះត្រូវអនុវត្ត និងរយៈពេលដែលវិធានការនោះមានប្រសិទ្ធិភាពអនុវត្ត ហើយគួរតែធ្វើបច្ចុប្បន្នភាពព័ត៌មាននេះឱ្យបានទៀងទាត់ និងអាចប្រើបានយ៉ាងទូលំទូលាយ។
- ឆាប់ៗតាមដែលអាចធ្វើទៅបាន វាជាការសំខាន់ណាស់សម្រាប់រដ្ឋាភិបាលនានា ក្នុងការធានាការវិលត្រឡប់មកជីវិតរស់ដូចធម្មតាឡើងវិញ និងមិនប្រើអំណាចបន្ទាន់ ដើម្បីគ្រប់គ្រងជីវិតប្រចាំថ្ងៃជារៀងរហូត ដោយទទួលស្គាល់ថា ការឆ្លើយតបត្រូវតែសមស្របទៅនឹងតម្រូវការនៃដំណាក់កាលផ្សេងៗគ្នានៃវិបត្តិនេះ។
- សូមមើលវិធានការបន្ទាន់ និងជំងឺកូវីដ-១៩ ៖ សេចក្តីណែនាំ (ជាឯកសារ PDF)